**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ**
**អគ្គលេខាធិការដ្ឋាន**
លេខ....................................

# សេចក្តីថ្លែងការណ៍

**របស់អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ (គ ជ ស ស)**

**ស្តីពីការផ្លាស់ប្តូរទីតាំងទីបញ្ជាការជួរមុខ របស់គណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ**

ដោយសារក្នុងពេលថ្មីៗនេះ មានការបកស្រាយដោយភ័ន្តច្រឡំតាមបណ្តាញព័ត៌មានខ្លះ អំពីការផ្លាស់ប្តូរទីតាំងទីបញ្ជាការជួរមុខ របស់ គ ជ ស ស អគ្គលេខាធិការដ្ឋាននៃ គ ជ ស ស សូមធ្វើការជូនដំណឹង និងបំភ្លឺ ដល់សាធារណជន ក៏ដូចជាមជ្ឈដ្ឋានជាតិ និងអន្តរជាតិ ឲ្យបានជ្រាបដូចតទៅ៖

ចាប់តាំងពីឆ្នាំ២០១០ ទីបញ្ជាការជួរមុខ ដែលជាអង្គភាពប្រតិបត្តិការអនុវត្តច្បាប់ចម្រុះស្ថាប័ន បានរៀបចំទីបញ្ជាការរបស់ខ្លួន ដោយស្នើសុំផ្នែកតូចមួយរបស់មូលដ្ឋានសមុទ្ររាម នៃកងទ័ពជើងទឹក ជាទីតាំងបណ្តោះអាសន្ន។ ស្ថិតក្រោមកម្មវិធីនៃកិច្ចសហប្រតិបត្តិការយោធាជាមួយប្រទេសជាដៃគូមួយចំនួន សហរដ្ឋអាមេរិក និងប្រទេសអូស្ត្រាលី បានផ្តល់ការគាំទ្រផ្នែកហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច និងការហ្វឹកហ្វឺន ដល់ទីបញ្ជាការជួរមុខ។ តែទោះជាដូច្នេះក្តី ដំណើរការនៃកិច្ចប្រតិបត្តិការរបស់ទីបញ្ជាការជួរមុខ បានប្រព្រឹត្តទៅប្រកបដោយលទ្ធផលចម្រុះ គឺជោគជ័យ និងការលំបាក ដែលតម្រូវឲ្យមានការគិតគូរអំពីការផ្លាស់ប្តូរទីតាំង។

ផ្អែកលើទស្សនៈនេះ អគ្គលេខាធិការដ្ឋាន គ ជ ស ស បានធ្វើការសិក្សាអំពីគម្រោងនៃការផ្លាស់ប្តូរទីតាំងនេះយ៉ាងល្អិតល្អន់ ចាប់តាំងពីចុងឆ្នាំ២០១៧ តរៀងមក។ អនុលោមតាមភាពចាំបាច់ និងស្មារតីសហប្រតិបត្តិការ អគ្គលេខាធិការដ្ឋានក៏បានធ្វើការជូនដំណឹង និងពន្យល់អំពីហេតុផល ដល់ប្រទេសជាដៃគូ ជាពិសេសសហរដ្ឋអាមេរិក **អំពីផែនការផ្លាស់ប្តូរទីតាំងនេះ** ហើយក៏ពុំបានទទួលនូវការជំទាស់ជាផ្លូវការណាមួយ ចំពោះការផ្លាស់ប្តូរនេះដែរ។

អាសយដ្ឋាន៖ ផ្លូវជាតិលេខ៦ សង្កាត់ជ្រោយចង្វា ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ (ក្នុងបរិវេណបញ្ជាការដ្ឋានកងទ័ពជើងទឹក) ទូរស័ព្ទ-ទូរសារ 023 68 51 159 អ៊ីម៉ែល: ncms.info@gmail.com

ការផ្លាស់ប្ដូរទីតាំងទីបញ្ជាការជួរមុខនេះ អនុលោមទៅតាមហេតុផលសំខាន់ៗមួយចំនួនដូចតទៅ៖

- ទីតាំងទីបញ្ជាការជួរមុខបច្ចុប្បន្ន ស្នាក់អាស្រ័យក្នុងបរិវេណមូលដ្ឋានកងទ័ពជើងទឹក មានទំហំតូច ធ្វើឲ្យប្រសិទ្ធភាពនៃកិច្ចប្រតិបត្តិការចម្រុះស្ថាប័ន មានកម្រិត និងជួបការលំបាក។ ឧទាហរណ៍ជាក់ ស្ដែងគឺទីតាំងនេះ ពុំមានផែសម្រាប់ចតនាវា ពុំអាចពង្រីករចនាសម្ព័ន្ធតទៅទៀតបាន និងមានការលំបាកសម្រាប់បុគ្គលិកមកពីស្ថាប័នស៊ីវិលនានា ក្នុងការចេញចូលក្នុងទីតាំងយោធា ដែលតម្រូវឲ្យមានការរឹតត្បិតផ្នែកសន្តិសុខ។

- ទីបញ្ជាការជួរមុខ ត្រូវការចាំបាច់នូវទីតាំងសមស្របមួយ ដែលប្រកបដោយភាពឯករាជ្យ ក្នុងឋានៈជាស្ថាប័នជាតិ ងាយស្រួលក្នុងការចេញប្រតិបត្តិការ ការធ្វើអន្តរាគមន៍ និងការជួយសង្គ្រោះ។ លើសពីនេះ ទីបញ្ជាការជួរមុខ ត្រូវការពង្រីក និងអភិវឌ្ឍសមត្ថភាពរបស់ខ្លួន ទាំងក្នុងផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងប្រសិទ្ធភាពនៃកិច្ចប្រតិបត្តិការ ដែលកិច្ចការនេះ ពុំអាចធ្វើបាន សម្រាប់ទីតាំងដែលនៅក្នុងមូលដ្ឋានសមុទ្ររាម។

- ដូច្នេះ នៅលើកោះព្រាប ដែលជាទីតាំងថ្មី មានអំណោយផលសម្រាប់ដោះស្រាយការលំបាក ដូចបានពោលខាងដើម។ អគ្គលេខាធិការដ្ឋាន គ ជ ស ស កំពុងដំណើរការសាងសង់ទីបញ្ជាការជួរមុខ នៅលើកោះព្រាប មានទំហំធំ និងចំនួនអាគារច្រើនជាងមុន **តែខិតខំជៀសវាងមិនឲ្យមានការបាត់បង់នូវសមិទ្ធិផល ដែលប្រទេសជាដៃគូ បានផ្ដល់ឲ្យផងដែរ។** ទីតាំងថ្មី របស់ទីបញ្ជាការជួរមុខ នឹងជួយសម្រួល និងបង្កើនប្រសិទ្ធិភាពប្រតិបត្តិការ ដោយមានការសាងសង់ផែសម្រាប់ចតនាវា ផ្ដល់ភាពងាយស្រួលនៅក្នុងទំនាក់ទំនងរវាងស្ថាប័នជាតិនានាដែលពាក់ព័ន្ធ ព្រមទាំងឯករាជ្យភាពសម្រាប់ការពង្រីកហេដ្ឋារចនាសម្ព័ន្ធ និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអន្តរជាតិ តទៅថ្ងៃអនាគត។

អគ្គលេខាធិការដ្ឋាន គ ជ ស ស នៅតែប្រកាន់ជំហរយ៉ាងម៉ឺងម៉ាត់ នៅក្នុងស្មារតីនៃការរក្សា និងលើកស្ទួយកិច្ចសហប្រតិបត្តិការជិតស្និត ជាមួយបណ្ដាប្រទេសជាដៃគូទាំងអស់ ប្រកបដោយតម្លាភាព និងការគោរពផលប្រយោជន៍គ្នាទៅវិញទៅមក។ គ ជ ស ស នៅតែស្វាគមន៍យ៉ាងកក់ក្ដៅបំផុត ចំពោះការចូលរួមពីសំណាក់ដៃគូអន្តរជាតិនានា ដើម្បីបង្កើនសមត្ថភាពផ្នែកប្រតិបត្តិការ

របស់ទីបញ្ហាការជួរមុខ តទៅថ្ងៃអនាគត។ យើងខ្ញុំសង្ឃឹមថា ជនរួមជាតិ ក៏ដូចជាមជ្ឈដ្ឋានជាតិ និងអន្តរជាតិ យល់អំពីហេតុផលពិតប្រាកដនៃដំណើរការនៃការផ្លាស់ប្តូរទីតាំងនេះ។ គោលដៅចម្បងរបស់យើងគឺបង្កើនប្រសិទ្ធភាពរបស់ គ ជ ស ស នៅក្នុងការបម្រើគោលនយោបាយរបស់រាជរដ្ឋាភិបាល នៅក្នុងវិស័យគ្រប់គ្រងសន្តិសុខលម្ហសមុទ្ររបស់កម្ពុជា និងការបន្តលើកស្ទួយកិច្ចសហប្រតិបត្តិការជាមួយអន្តរជាតិ ប្រកបដោយតម្លាភាព និងការគោរពផលប្រយោជន៍គ្នាទៅវិញទៅមក។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៥ ខែតុលា ឆ្នាំ២០២០

**អគ្គលេខាធិការដ្ឋាន គ ជ ស ស**